00944803

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 14 / 08 / 2013
ម៉ោង (Time/Heure) : 16:50
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

E298

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

# អង្គជំនុំជម្រះសាលាដំបូង

**ជូនចំពោះ÷** ភាគីនៃសំណុំរឿង ០០២ កាលបរិច្ឆេទៈ ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០១៣

**ពី÷** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន÷** លោក /លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ÷** សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា សុំដាក់ឯកសារ D366/7.1.366 នៅចំពោះមុខអង្គជំនុំជម្រះ ដោយអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង

១. សហព្រះរាជអាជ្ញាបានស្នើសុំដោយផ្ទាល់មាត់កាលពីថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៣ ដើម្បីដាក់នៅចំពោះមុខអង្គជំនុំជម្រះនូវអនុស្សរណៈមួយរបស់ក្រុមប្រឹក្សាសន្តិសុខជាតិ ដែលមានចំណងជើងថា "ព័ត៌មានសំខាន់ៗអំពីកម្ពុជា" ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ១៩៧៥ (ឯកសារ D366/7.1.366)[1]។ ពួកគាត់លើកឡើងថា ថ្វីបើពួកគាត់ពុំមានលទ្ធភាពបង្ហាញអំពីការយកចិត្ត

---

[1] អង្គជំនុំជម្រះកត់សម្គាល់ថា ឯកសារនេះត្រូវបានចងអង្គុលបង្ហាញដោយភាន់ច្រឡំដោយក្រុមមេធាវីការពារក្តី អៀង សារី ដូច្នេះហើយអង្គជំនុំជម្រះក៏បានដាក់ឯកសារនេះចូលដោយភាន់ច្រឡំទៅក្នុង "សេចក្តីសម្រេចលើកទីបីលើការជំទាស់ទៅនឹងឯកសារដែលបានស្នើសុំឲ្យទទួលយកនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង" ឧបសម្ព័ន្ធ ង (ឯកសារ E185/2.5) ទំព័រ ៣ ។ សំណើសុំកែតម្រូវលើឯកសារនេះនឹងធ្វើឡើងក្នុងពេលសមស្រប ដោយលុបឯកសារនេះចេញពីឧបសម្ព័ន្ធ ។

ទុកដាក់ត្រឹមត្រូវនៅក្នុងការស្វែងរកភស្តុតាងដែលត្រូវបានស្នើសុំដាក់នេះក៏ដោយ ក៏ឯកសារនេះ "ពាក់ព័ន្ធជាពិសេស" ហើយការទទួលយកឯកសារនេះនឹងជាផលប្រយោជន៍នៃយុត្តិធម៌ (ប្រតិចារឹក ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៣ ទំព័រ ៥៨-៦០, ៧៧-៨៣)។ មេធាវីការពារក្តី ខៀវ សំផន ជំទាស់ ដោយលើកអំណះអំណាងថា សហព្រះរាជអាជ្ញាបានខកខានពុំបានធ្វើសំណើជាលាយលក្ខណ៍អក្សរ ដែលមានសំអាងហេតុ បានទាន់ពេលវេលា ដែលបំពេញលក្ខណវិនិច្ឆ័យដូចមានចែងនៅក្នុងវិធាន ៨៧(៣) និងវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង (ប្រតិចារឹក ថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ២០១៣ ទំព័រ ៥៥-៦៨ (ភាសាអង់គ្លេស))។

២. អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះអាចទទួលយកភស្តុតាងថ្មីៗនានា ដែលខ្លួនយល់ថាអាចនាំទៅដល់ការបញ្ជាក់ការពិត នៅក្នុងករណីដែលភស្តុតាងនោះបំពេញបទដ្ឋាននៃ *ការពិនិត្យជាបឋម* ទៅលើភាពពាក់ព័ន្ធ ភាពអាចជឿជាក់បាន និងយថាភាព ដែលវិធាន ៨៧(៣) បានតម្រូវ។ ភាគីធ្វើសំណើ ត្រូវតែធ្វើឲ្យអង្គជំនុំជម្រះជឿជាក់ថា ភស្តុតាងដែលត្រូវបានស្នើសុំដាក់ ពុំអាចរកបាននៅមុនពេលបើកសវនាការ ឬពុំអាចត្រូវបានរកឃើញនៅពេលមុន ទោះបីជាមានការយកចិត្តទុកដាក់ត្រឹមត្រូវក៏ដោយ។ យ៉ាងណាមិញ នៅក្នុងករណីជាក់លាក់មួយចំនួន អង្គជំនុំជម្រះបានទទួលយកភស្តុតាងដែលពុំបំពេញលក្ខណវិនិច្ឆ័យនេះ នៅក្នុងករណីដែលផលប្រយោជន៍នៃយុត្តិធម៌តម្រូវដូច្នេះ (ឯកសារ E190, កថាខណ្ឌ 19-21; ឯកសារ E289/2, កថាខណ្ឌ ៣)។

៣. ជាបឋម សហព្រះរាជអាជ្ញាបានស្នើសុំដាក់ភស្តុតាងដែលត្រូវបានស្នើសុំដាក់ នៅក្នុងសំណុំរឿងកាលពីថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១០ (ឯកសារ D366)។ បន្ទាប់មកទៀត សហចៅក្រមស៊ើបអង្កេតបានដាក់ភស្តុតាងដែលត្រូវបានស្នើសុំដាក់នេះនៅក្នុងសំណុំរឿង កាលពីថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១០ (ឯកសារ D366/7)។ យ៉ាងណាមិញ សហព្រះរាជអាជ្ញាពុំបានដាក់បញ្ចូលភស្តុតាងដែលត្រូវបានស្នើសុំដាក់នេះនៅក្នុងបញ្ជីភស្តុតាងរបស់ខ្លួន ដែលត្រូវបានស្នើសុំដាក់ដោយអនុលោមតាមវិធាន ៨០(៣) ឡើយ។ ពួកគាត់ទទួលស្គាល់ថា ពួកគាត់ពុំអាចផ្តល់យុត្តិកម្មចំពោះការស្វែងរកពុំទាន់ពេលវេលា និងការបង្ហាញភស្តុតាងនេះក្នុងអំឡុងសវនាការលើឯកសារគន្លឹះជាចុងក្រោយ នៅក្នុងសំណុំរឿង ០០២/០១ និងរយៈពេលជាង ៣ ឆ្នាំបន្ទាប់ពីភស្តុតាងនេះត្រូវបានដាក់ជាដំបូងនៅក្នុងសំណុំរឿង (ប្រតិចារឹក ថ្ងៃទី ២៤ ខែ

មិថុនា ឆ្នាំ ២០១៣ ទំព័រ ៨០ (ភាសាអង់គ្លេស))។ ហេតុដូច្នេះ សហព្រះរាជអាជ្ញាខកខានពុំបានបំពេញលក្ខណវិនិច្ឆ័យដូចមានចែងនៅក្នុងវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងឡើយ។

៤. អង្គជំនុំជម្រះកត់សម្គាល់ឃើញផងដែរថា ផ្នែកនៃភស្តុតាងដែលត្រូវបានស្នើសុំដាក់ ដែលសហព្រះរាជអាជ្ញាបានកំណត់ជាភស្តុតាងពាក់ព័ន្ធជាពិសេស (ប្រតិចារឹក ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៣ ទំព័រ ៨០ (ភាសាអង់គ្លេស), ឯកសារ D366/7.1.366, ERN 00443226-8) ត្រួតជាន់គ្នា និង/ឬ ផ្អែកលើប្រភពដូចគ្នា ជាមួយភស្តុតាងដទៃទៀតដែលស្ថិតនៅចំពោះមុខអង្គជំនុំជម្រះរួចហើយ ដែលបរិយាយអំពីរបាយការណ៍របស់ប្រជាជនអៀសខ្លួនស្តីពីការផ្លាស់ទីលំនៅដោយបង្ខំ និងការសម្លាប់ នៅមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ (*សូមមើលឧទាហរណ៍* ឯកសារ E3/30; E3/120; E3/3472 )។ ហេតុដូច្នេះ អង្គជំនុំជម្រះពិចារណាឃើញថា សហព្រះរាជអាជ្ញាបានខកខានពុំបានចង្អុលបង្ហាញថា ការទទួលយកភស្តុតាងនេះគឺដើម្បីជាផលប្រយោជន៍នៃយុត្តិធម៌ ពិសេសនៅដំណាក់កាលចុងបញ្ចប់នៃសវនាការនេះ។ អង្គជំនុំជម្រះសម្រេចបដិសេធសំណើសុំទទួលយកឯកសារ D366/7.1.366។

៥. នេះជាចម្លើយតបជាផ្លូវការរបស់អង្គជំនុំជម្រះទៅនឹងសំណើរបស់សហព្រះរាជអាជ្ញានៅក្នុងសវនាការកាលពីថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៣ (ប្រតិចារឹក ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៣ ទំព័រ ៥៨-៦០, ៧៧-៨៣ (ភាសាអង់គ្លេស))។